# ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## Ministry of Industry and Handicraft (MIH)

# វិទ្យាស្ថានស្តង់ដារកម្ពុជា

## Institute of Standards of Cambodia (ISC)

បាត់ដំបង ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦

1

# បទបង្ហាញ ស្តីពីហានីភ័យដល់សុខភាព ដោយសារជាតិគីមី និងមេរោគ ចំពោះ ផលិតផលគុយទាវ/មីសសៃ សាច់ប្រហិត/ប៉ាតេ/ណែម

2

# ១) សេចក្តីផ្តើម

- នៅក្នុងវត្ថុអ្វីក៏មានជាតិពុលដែរ ហើយគ្មានអ្វីដែលមិនពុលទេ! (ប្រសាសន៍របស់អ្នកប្រាជ គីមីសតវត្សទី១៦ ឈ្មោះ ប៉ារ៉ាសែលស៊ុល)
- គឺបរិមាណរបស់វា ដែលហៅថា «ដូស» កំណត់ថាវាជា **ថ្នាំព្យាបាល** ឬ **ជាថ្នាំពុល**?
- យើងទាំងអស់គ្នាត្រូវបានចោមរោមដោយសារធាតុគីមី គេចមិនផុតពីជាតិគីមីឡើយ
- ប្រើការយល់ដឹង និងការពិសោធន៍ទាំងឡាយដែលមនុស្សជាតិមាន ដើម្បីដកចេញនូវសារធាតុគីមីទាំងឡាយដែលមានគ្រោះថ្នាក់ជាក់ស្តែង
- ទោះបីមិនទាន់មានភ័ស្តុតាងគ្រប់គ្រាន់ពីគ្រោះថ្នាក់របស់វាក្តី គប្បីកាត់បន្ថយការប្រើប្រាស់គ្រប់សារធាតុគីមីឲ្យនៅចំនួន និងបរិមាណអប្បបរមាបំផុត តាមដែលអាចធ្វើទៅបាន។

3

# ១) សេចក្តីផ្តើម (ត)

**ផ្លូវជ្រាបចូលនៃសារធាតុពុល**

- តាមផ្លូវអាហារ
- តាមផ្លូវដង្ហើម
- តាមការចាក់បញ្ចូលតាមសសៃ (ចាក់ថ្នាំ)
- តាមការប៉ះផ្ទាល់ (ស្បែក)

4

## ២) អ្វីទៅជាជាតិបរ៉ាក់?

- គេនិយមហៅ បរ៉ាក់ ($Na_2B_4O_7.10H_2O$) ឬសូដ្យូមតេត្រាបរ៉ាត ថាជាទឹកអន្សា។



- វាជាអង្គធាតុសមាសដែលមានជាតិបរ៉ុន។ ជាសារធាតុខនិចម្យ៉ាង ដែលមានលក្ខណៈជាក្រាម ឬជាម្សៅពណ៌ស និងងាយរលាយក្នុងទឹក។
- អង្គធាតុទោលបរ៉ុន គឺជាអលោហៈដែលមិនកើតមានដោយឯកឯងនៅក្នុងធម្មជាតិទេ។ វាកើតមានជាទម្រង់បរ៉ាត ដែលសមាសធាតុនេះ កើតមានដោយការចងសម្ព័ន្ធជាមួយសារធាតុផ្សេងៗទៀតនៅក្នុងបរិស្ថាន។
- សម្រាប់ការលូតលាស់របស់រុក្ខជាតិ  អង្គធាតុទោលបរ៉ុន ក៏ជាជាតិបំប៉នដ៏សំខាន់ផងដែរ។
- អាស៊ីតបរិក និងបរ៉ាក់ វាកើតមានជាធម្មជាតិនៅក្នុងទឹក និងដី។

5

## ២) ការកើតមានជាតិបរ៉ាក់ ដោយឯកឯងនៅក្នុងធម្មជាតិ

- បរ៉ុន មាននៅក្នុងម្ហូបអាហារជាទម្រង់បរ៉ាត ឬអាស៊ីតបរិក។
- ប្រភពដែលសំបូរបរ៉ុនជាងគេ មាន ៖ ផ្លែឈើ បន្លែ គ្រាប់ធញ្ញជាតិដូចជា សណ្ដែកដី។
- ស្រាទំពាំងបាយជូរ ស្រាផ្លែប៉ោម និងស្រាបៀរ ក៏អាចមានក្នុងកម្រិតខ្ពស់។
- ផលិតផលទឹកដោះគោ ត្រី សាច់ និងគ្រាប់ធញ្ញជាតិស្ទើរតែទាំងអស់ អាចមានក្នុងកម្រិតតិចតួច។

6

# កម្រិតនៃជាតិបរ៉ុនដែលរកឃើញមាននៅក្នុងម្ហូបអាហារមួយចំនួន

| ប្រភេទម្ហូបអាហារ | ឈ្មោះម្ហូបអាហារ | កម្រិតជាតិ បរ៉ុន ( mg/kg ) |
|---|---|---|
| ផ្លែឈើ | ផ្លែប៉ោម | 2.38 - 2.73 |
| | ផ្លែចេក | 3.72 |
| គ្រាប់សណ្តែក | Almonds | 23 |
| | សណ្តែកដី | 13.8 - 18 |
| ភេសជ្ជៈ | ស្រាបៀរ | 0.13 - 1.8 mg/L |
| | ស្រាទំពាំងបាយជូរ | 3.5 mg/L |
| ផលិតផលពីគ្រាប់ធញ្ញជាតិ | នំប៉័ង | 0.20 - 0.48 |
| | បបរ | ≤0.015 |

7

# ៣) មុខសញ្ញាប្រើប្រាស់

បរ៉ាក់ ត្រូវបានគេប្រើប្រាស់ក្នុងមុខងារច្រើនយ៉ាង ៖

- ប្រើសម្រាប់ផ្សំសាប៊ូ
- ប្រើសម្រាប់ធ្វើឲ្យរលោង
- ប្រើក្នុងមន្ទីរពិសោធន៍គីមី និងគីមីជីវៈ
- ប្រើសម្រាប់ការផ្សារដែក ដែលថែប និងគ្រឿងអលង្ការលោហៈ ដូចជា មាស ឬប្រាក់
- គ្រឿងផ្សំក្នុងថ្នាំលាបឲ្យរលោង
- ប្រើសម្រាប់ផ្សំក្នុងការកញ្ចក់ គ្រឿងព័រសីឡែន ចាន ឆ្នាំង
- ថ្នាំសម្លាប់សត្វល្អិត ស្រមោច កន្លាត និងចៃឆ្កែ
- វាធ្លាប់ត្រូវបានគេយកទៅប្រើជាថ្នាំជំងឺផ្សិត
- ពន្លត់អគ្គីភ័យ។ល។

8

# ៤) សារធាតុគីមីហាមប្រើប្រាស់ក្នុងផលិតផលម្ហូបអាហារ និងផលប៉ះពាល់ដល់សុខភាព

Borax ឬទឹកអន្សា

- ភាគច្រើន Borax ត្រូវបានគេដាក់ដោយខុសច្បាប់ក្នុងសាច់ប្រហិត សាច់ប៉ាតេ ណែម គុយទាវសសៃ មីសសៃ ចាហួយ លតស្ងិត នំបាញ់ហយ នំបញ្ចុក នំបាញ់ឆុក នំចាំង។ល។ ដើម្បីឲ្យស្វិត។
- ជាសារធាតុដែលប៉ះពាល់ដល់សុខភាព បង្កឲ្យមានជំងឺតម្រងនោម ខួរក្បាល ប្រព័ន្ធក្រពះពោះវៀន ថ្លើម បន្ថយការបង្កើតគោលិកាឈាមក្រហម។ល។
- ការទទួលទានម្ហូបអាហារដែលមានជាតិបរ៉ាក់ក្នុងកម្រិតច្រើន និងរយៈពេលមួយដ៏ខ្លី អាចបណ្ដាលឲ្យ ៖ រាគ ក្អួត ឈឺចុកមួលពោះ រលាកក្រពះ ពោះវៀន ថ្លើម តម្រងនោម ប៉ះពាល់ដល់ខួរក្បាល ខូចសសៃឈាម រត់ហើយអាចបណ្ដាលឲ្យស្លាប់បាន។
- តាមរយៈការដកដង្ហើម បង្កឲ្យមានជំងឺផ្លូវដង្ហើម ក្អក ឬថប់ផ្លូវដង្ហើម។
- តាមរយៈការប៉ះពាល់ផ្ទាល់ ធ្វើឲ្យស្បែកឡើងកន្ទួល រមាស់ រលាកស្បែក។
- បើបរិមាណ ១៥ក្រាម ចំពោះមនុស្សចាស់ និងក្មេង ៥ ទៅ ១០ក្រាម ធ្វើឲ្យក្អួតឈាមស្លាប់។
- វាត្រូវបានបញ្ចេញចោលតាមទឹកនោម (៥ ទៅ ៧ថ្ងៃ ចេញបាន ៨៥ ទៅ ១០០% នៃដូសដែលចូល)។

9

# ៣) សារធាតុគីមីហាមប្រើប្រាស់ក្នុងផលិតផលម្ហូបអាហារ និងផលប៉ះពាល់ដល់សុខភាព(ត)

Formalin ឬហ្វ័រម៉ុល

- គេប្រទះឃើញប្រើដោយខុសច្បាប់សម្រាប់ត្រាំបន្លែស្រស់ បង្គាស្រស់ មឹកស្រស់ ត្រីងៀត សាច់ប្រហិត តៅហ៊ូ និងសាច់ស្រស់ផ្សេងៗទៀត ។ល។ ដើម្បីកុំឲ្យស្អុយ រក្សាពណ៌សម្បុរបានយូរ និងមិនឲ្យរុយរោមសាច់ស្រស់។
- ជាសារធាតុដែលប៉ះពាល់ដល់សុខភាព បណ្ដាលឲ្យឈឺក្រពះ ក្អួត រាគ បាត់បង់ស្មារតី ហើយស្លាប់។ វាជួយជំរុញឲ្យកើតជំងឺមហារីកនៅច្រមុះ និងក្នុងបំពង់ក។
- បើចូលភ្នែកអាចបណ្ដាលឲ្យខ្វាក់។ បើហឺតចូលសួត បណ្ដាលឲ្យរលាកបំពង់ខ្យល់ ហើមសួត រលាកទងសួត ហត់មានលក្ខណៈស្រដៀងកើតហឺត។
- បើផឹកចូលអាចប្រកាច់ សន្លប់ ចុកចាប់ក្នុងពោះ សភាពហ្ស៊ុក ឬអាចស្លាប់។ ជាលិកាដែលប៉ះជាមួយវានឹងស្លោកខូច។

10

# ៣) សារធាតុគីមីហាមប្រើប្រាស់ក្នុងផលិតផលម្ហូបអាហារ និងផលប៉ះពាល់ដល់សុខភាព(ត)

ហាមប្រើល័ក្ខពណ៌សំយោគ ដូចជា ៖

-SUDAN I, SUDAN II, SUDAN III & SUDAN IV

-ACID ORANGE II

- អាចបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព
- ដូចជាកើតជំងឺមហារីក ហឺត និង Allergic។




11

# ៤) បទប្បញ្ញត្តិបច្ចេកទេស ស្ដីពីការហាមប្រើជាតិប៉ាក់ក្នុងផលិតផលម្ហូបអាហារ

១) យោងតាមច្បាប់ស្តង់ដារស្តីពីម្ហូបអាហារ សារជាតុបរ៉ាក់ មិនអនុញ្ញាតឲ្យប្រើនៅក្នុងម្ហូបអាហារឡើយ។

២) ប្រកាសលេខ១៨៣ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីសារជាតុគីមីហាម

- ដាក់បញ្ចូលក្នុងផលិតផលម្ហូបអាហារ
- ដាក់ឲ្យប៉ះទៅនឹងផលិតផលម្ហូបអាហារ ឬ
- រក្សាទុកដោយពុំមានហេតុផលត្រូវច្បាប់

នូវសារជាតុគីមីហាមឃាត់ ដូចជា Borax, Boric Acid, Formaldehyde, Paraformaldehyde, Para Red, Rhodamine B, Salicylic Acid, Sudan I, Sudan II, Sudan III and Sudan IV។

12

## ៥) កម្រិតអនុញ្ញាតអតិបរិមា ដែលទាក់ទងទៅនឹងជាតិអាស៊ីតបរិក និងប៉ាក់ ក្នុងផលិតផលម្ហូបអាហារ

- ដោយសារវាអាចមាននៅក្នុងធម្មជាតិ ដូចនេះ កម្រិតជាតិប៉ាក់ (គិតជាអាស៊ីតបរិក) ត្រូវតែតូចជាង 10mg/Kg នៃផលិតផល។
- ការធ្វើតេស្តរកជាតិប៉ាក់ គឺជាការវាយតម្លៃតាមដានថា ៖ ផលិតផលម្ហូបអាហារមានបរិមាណជាតិប៉ាក់ គ្រប់គ្រាន់ដែលអាចបញ្ជាក់បានថា អាចត្រូវបានគេដាក់ប្រើដោយខុសច្បាប់នៅក្នុងវត្ថុជាតិដើម គ្រឿងផ្សំ និងក្នុងពេលផលិត។

13

## ៦) ស្តង់ដារសុវត្ថិភាព ដែលទាក់ទងនឹងមេរោគបង្កជំងឺ

- ការធ្វើតេស្តដោយផ្តោតលើសុវត្ថិភាពម្ហូបអាហារផ្នែកមីក្រូជីវសាស្ត្រ គឺជាការតាមដានវាយតម្លៃ ថាតើ ផលិតផល មានចំនួនមេរោគបង្កជំងឺ និងជាតិពុលតុកស៊ីនគ្រប់គ្រាន់ ដែលអាចបណ្តាលឲ្យមានការពុលម្ហូបអាហារ ឬទេ?
- ប្រសិនបើផលិតផលម្ហូបអាហារ មានមេរោគបង្កជំងឺក្នុងបរិមាណដ៏ច្រើន ឬមានជាតិពុលតុកស៊ីន ហើយត្រូវបានគេយកវាទៅចម្អិនដោយការដាំស្ងោរនោះ គឺមិនអាចរំងាប់មេរោគ ឬបំផ្លាញតុកស៊ីនបានទាំងស្រុងទេព្រោះមេរោគមួយចំនួនដែលមានស្ព័រ និងជាតិពុលតុកស៊ីន ធន់នឹងកំដៅណាស់(ចំពោះ Coliform និង *E. coli* អាចងាប់នៅសីតុណ្ហភាព ៧៥អង្សារសេ រយៈពេល ១៥នាទី)
- តែប្រសិនបើផលិតផលទាំងនោះ ត្រូវបានគេចម្អិនវាជាមួយនឹងប្រេងឆា ក្នុងរយៈពេលមួយដែលគ្រប់គ្រាន់ ទើបអាចរំងាប់មេរោគ និងបំផ្លាញជាតិពុលតុកស៊ីនបានទាំងស្រុង។

14

# ៦) ស្តង់ដារសុវត្ថិភាព ដែលទាក់ទងនឹងមេរោគបង្កជំងឺ

- ចំនួនមីក្រូសរីរាង្គសរុប (Total Plate count) មិនត្រូវលើសពី ១.០០០.០០០កូឡោនី/ក្រាមផលិតផលសម្រេច
- ចំនួនមេរោគ *Coliform* មិនត្រូវមានលើសពី ៥០កូឡោនី/ក្រាមផលិតផល
- ចំនួនមេរោគ *E. coli* មិនត្រូវបានរកឃើញមាននៅក្នុង១ក្រាមផលិតផលឡើយ
- ចំនួន Moulds និង Yeast មិនត្រូវមានលើសពី ៥០កូឡោនី/ក្រាមផលិតផល
- ចំនួនមេរោគ *Salmonella* មិនត្រូវបានរកឃើញមាននៅក្នុង២៥ក្រាមផលិតផលឡើយ។
- ចំនួនមេរោគ Coagulase Positive Staphylococci មិនត្រូវមានលើសពី ១០.០០០កូឡោនី/ក្រាមផលិតផល
- ចំនួនមេរោគ *Listeria monocytogenes* មិនត្រូវមានលើសពី ១០០កូឡោនី/ក្រាមផលិតផល
- ចំនួនមេរោគ *Bacillus cereus* មិនត្រូវមានលើសពី ១០.០០០កូឡោនី/ក្រាមផលិតផល។

15

# *Escherichia coli* (not detected)

ថ្វីបើ *E. coli* មួយចំនួនមិនបង្កឲ្យមានជំងឺផ្នែកក្រពះ ពោះវៀនក៏ដោយ ក៏មានប្រភេទខ្លះ ដែលបង្កឲ្យមានជំងឺចុកពោះ រាគរូស ក្អួតចង្អោរ។

•កំឡុងពេលចាប់ផ្តើមធ្វើទុក ជាទូទៅ គឺ ពី ៣ ទៅ ៤ថ្ងៃ

•រោគសញ្ញា ៖ វិលមុខ រាគ (ជួនកាលមានឈាម) និងឈឺចុកមួលក្នុងពោះយ៉ាងខ្លាំង។

16

# *Escherichia coli*

គេចែក *E. coli* ជា ៥ក្រុម ៖

- ETEC ( Enterotoxigenic *E. coli*) អាចបណ្តាលឲ្យមានជំងឺរាគរូសជាញឹកញាប់ទៅលើទារក។
- EPEC ( Enteropathogenic *E. coli*) អាចបណ្តាលឲ្យមានជំងឺរាគរូសរលាកពោះវៀនទៅលើកុមារ។
- EHEC ( Enterohemorrhagic *E. coli*) អាចបណ្តាលឲ្យមានជំងឺរាគឈាម និងមានឈាមស្រស់មកជាមួយ។ បរិមាណដែលអាចឆ្លងមានកម្រិតទាប ( ១០មីក្រូសរីរាង្គ )។
- EIEC ( Enteroinvasive *E. coli*) ជាញឹកញាប់រាគឈាម កើតមានលើអ្នកជំងឺគ្រប់វ័យ។
- EAggEC ( Enteroaggregative *E. coli*) អាចបណ្តាលឲ្យមានជំងឺរាគរូសរ៉ាំរ៉ៃ ជាពិសេសលើកុមារ។

17

# *E. coli* 0157:H7

- គេច្រើនប្រទះឃើញនៅក្នុងពោះវៀន សត្វជ្រូក គោ ក្របី ពពែ និងមនុស្ស ទឹកស្អុយ សាច់ និងទឹកដោះគោឆៅ។
- *E.coli 0157* ដែលអាចមានលទ្ធភាពក្នុងការធ្វើឲ្យតម្រងនោមកុមារអន់ខ្សោយ និងពេលខ្លះអាចបណ្តាលឲ្យមនុស្សវ័យចំណាស់ស្លាប់បាន។
- វាបង្កើតតុកស៊ីនមួយដែលស្រដៀងគ្នាទៅនឹងជាតិពុលតុកស៊ីនម្យ៉ាងដែលបង្កើតដោយមេរោគរាគមូល ឈ្មោះ *Shigella*។
- ឆ្លង និងការកើតមានមហន្តរាយដែលពាក់ព័ន្ធទៅនឹង *E. coli* 0157:H7 គឺមានការជាប់ជំពាក់ទាក់ទងម្តងម្កាលជាមួយនឹងទឹកដែលមានការកង្វក់ប៉ុន្តែជាចម្បងជាងគេ គឺការឆ្លងដែលបណ្តាលមកពីម្ហូបអាហារ ហើយការឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក៏កើតមានឡើងផងដែរ។

18

# *E. coli* 0157:H7

- នៅពេលសម្លាប់សត្វ បាក់តេរីនេះអាចចម្លងទៅសាកសពសត្វបាន។
- វាជាមេរោគបង្កជំងឺមួយដ៏មានគ្រោះថ្នាក់ ហើយដែលវាអាចទ្រាំរស់បានទាំងនៅពេលរក្សាវាទុកក្នុងទូរទឹកកក និងទូរបង្កក។
- វាក៏អាចទ្រាំរស់បានយ៉ាងល្អនៅក្នុងមជ្ឈដ្ឋានអាស៊ីតរហូតដល់កម្រិត pH ចុះដល់ ៤,០។
- នីតិវិធីដែលបានប្រើសម្រាប់រំងាប់ *E.coli 0157:H7* រួមមានការផ្សំគ្នារវាងកម្រិត pH, Aw និងសីតុណ្ហភាព។
- វាលូតលាស់បំបែកកូនថៅយ៉ាងយឺតបំផុតនៅក្នុងសីតុណ្ហភាពទូរទឹកកក។
- តាមរយៈការចម្អិន វាគឺជាវិធីសាស្រ្តមួយដែលគួរឲ្យជឿជាក់បានដើម្បីរំងាប់មេរោគបង្កជំងឺនេះ។

19

# ផ្សិត

- ជារឿយៗ ផ្សិត គឺជាអ្នកទទួលខុសត្រូវលើការខូច ជូរ ផ្អូម របស់ម្ហូបអាហារ ជាសំខាន់ លើផលិតផល គុយទាវសើម នំប៉័ង និងផ្លែឈើដែលទុកយូរ និងមិនសមស្រប។
- ផ្សិតខ្លះបង្កើតជា មីកូតុកស៊ីន ដែលបង្កជាជំងឺមកពីជាតិពុល ហើយបណ្តាលឲ្យកើតមានជំងឺមហារីក និងពេលខ្លះបណ្តាលឲ្យស្លាប់។

20

## Coagulase Positive Staphylococci (<10.000cfu/g) Staphylococcal enterotoxin (not detected)

- វាមានវត្តមាននៅក្នុងច្រមុះ មាត់ បំពង់ក លើស្បែក និងសក់ នៃមនុស្សដែលមានសុខភាពល្អគ្រប់រូប និងស្នាមរលាក មុត។ ការក្អក និងកណ្តាស់ អាចព្រួសចេញក្រៅនូវមេរោគក្នុងចម្ងាយមួយដ៏សមស្រប និងជនដែលមានជំងឺផ្តាសាយ មិនត្រូវប៉ះពាល់ ឬនៅជិតផលិតផលដែលបើកចំហរទេ។ កំទេចកំទីចេញពីត្រចៀក (អាចម៍ត្រចៀក) ភ្នែក និងច្រមុះ អាចចម្លងដល់ម្ហូបអាហារបាន។ ក្នុងផលិតកម្ម ការបោះចោលកន្សែង ក្រដាស់ ដែលប្រើតែម្តងក្នុងការជូតដៃ គឺប្រសើរជាងប្រើកន្សែងដៃ ក្រណាត់ជូតដៃច្រើនគ្នាច្រើនដង។
- ជាញឹកញាប់ ការកើតមានបណ្តាលមកពីការកាន់ប៉ះពាល់ផ្ទាល់ដៃមនុស្ស (ម្ហូបអាហារដែលបានចំអិនរួច និងនៅស្រស់) ហើយគេអាចគ្រប់គ្រងវាបានដោយការធ្វើអនាម័យដៃ និងការប្រើប្រាស់ស្រោមដៃដែលប្រើម្តងហើយត្រូវបោះវាចោល។

21

## Coagulase Positive Staphylococci (<10.000cfu/g)

## Staphylococcal enterotoxin (not detected)

- វាអាចរស់នៅក្នុងផលិតផលដែលមានជាតិអំបិលសម្បូរហួតដល់ ១៥%។
- ការគ្រប់គ្រងវាដោយប្រើកំដៅ ជាមធ្យោបាយមួយដ៏ល្អជាងគេ ដើម្បីកាត់បន្ថយនូវការលូតលាស់បង្កើតកូនចៅនៃ *S. aureus* និងការកើតមានឡើងនូវជាតិពុលតុកស៊ីន ហើយគេអាចរំងាប់មេរោគនេះដោយប្រើកំដៅល្មម។
- មេរោគនេះ ចាប់ផ្តើមលូតលាស់យ៉ាងខ្លាំង នៅសីតុណ្ហភាព ធំជាង ១៥,៦អង្សាសេ។
- ការបន្ទាបកម្រិត pH <5.3 ធ្វើឲ្យការលូតលាស់នៃ *S. aureus* មានសភាពយឺត។
- កំឡុងពេលចាប់ផ្តើមធ្វើទុក ជាទូទៅ គឺពី ១ ទៅ ៧ម៉ោង។
- រោគសញ្ញា ធ្វើឲ្យឈឺចុកចាប់ក្នុងពោះ ច្រើនក្អួតចង្អោរ មានចុះរាគខ្លះ អស់កម្លាំងល្អិតល្ហៃ សីតុណ្ហភាពមិនប្រក្រតី គ្រុនក្តៅមានបន្តិចបន្តួច (៦ ទៅ ២៤ម៉ោង)។

22

# *Salmonella* species (not detected)

គេច្រើនប្រទះឃើញមេរោគនេះមាននៅក្នុងពោះវៀនសត្វចៀម គោក្របី ជ្រូក និងបក្សី នៅក្នុងសាច់ឆៅ ទឹកដោះគោឆៅ ស៊ុតឆៅ កណ្ដុរ សាច់សត្វស្លាបឆៅ រុយ ព្រាប ផ្លែ ផ្កា ទឹកផឹក ទឹកសំណល់។

*Salmonella typhi* ដែលគេស្គាល់ថា ជាមេរោគគ្រុនពោះវៀន

- កំឡុងពេលចាប់ផ្ដើមធ្វើទុក ជាទូទៅ គឺពី ១២ ទៅ ១៨ម៉ោង
- រោគសញ្ញា ធ្វើឲ្យចុកចាប់ក្នុងពោះ ចុះរាគ ក្អួត និងក្ដៅខ្លួន គ្រុនរសោប់រសល់ ឈឺក្បាល (១ ទៅ ៣សប្ដាហ៍)។

23

# *Salmonella* species (not detected)

- វាអាចលូតលាស់ដោយមាន ឬគ្មានអុកស៊ីសែន និងក្នុងចន្លោះសីតុណ្ហភាពពី ៥ ទៅ ៤៧អង្សាសេ និងក្នុងកម្រិត pH ទាប។
- វាមិនអាចលូតលាស់ នៅសីតុណ្ហភាពលើសពី ៥៤អង្សាសេ និងក្នុងកម្រិត pHទាប។
- *Salmonella* ងាយងាប់នឹងកំដៅ ហើយការចម្អិនសាច់នៅសីតុណ្ហភាពពី ៦៥ ទៅ ៧៤អង្សាសេ នឹងអាចកំទេចវាបានយ៉ាងលឿន។

24

## *Listeria monocytogenes* (<100cfu/g)

- មេរោគនេះមានសមត្ថភាពបង្កើតកូនចៅ ក្រោម ៣អង្សារសេ ទោះជាមានកម្រិតឃើតយ៉ាងណា និងមាននៅក្នុងបរិស្ថាន ទាំងសត្វ មនុស្ស ទឹកស្អុយ និងទឹកដោះគោឆៅ។
- វាមានវត្តមាននៅក្នុងដី បន្លែ ទឹក និងអាចចម្លងដោយមនុស្ស និងសត្វ។
- វាអាចត្រូវបានគេរកឃើញក្នុងបរិមាណផ្សេងៗគ្នា នៅក្នុងចង្វាក់នៃប្រព្រឹត្តកម្មសាច់ និងក្នុងផលិតផលសាច់ផ្សេងៗជាច្រើន។

25

## *Listeria monocytogenes* (<100cfu/g)

- វាអាចលូតលាស់ដោយមាន ឬដោយគ្មានអុកស៊ីសែន វាអាចទ្រាំរស់នៅក្នុងលក្ខខណ្ឌស្ងួត និងវាជាមីក្រូសរីរាង្គមួយដែលធន់នឹងអំបិលសម្លខ្លាំង (very salt-tolerant)។
- នៅសីតុណ្ហភាព ៤អង្សាសេ បាក់តេរីនេះអាចបំបែកខ្លួនបានជាពីរកោសិកាក្នុងរវាង ១,៥ ថ្ងៃ។
- នៅក្នុងណែមជូរ *L. monocytogenes* គឺត្រូវបានគេគ្រប់គ្រងតាមរយៈការផ្សំគ្នារវាងកម្រិត pH ទាប ជាតិអំបិលសម្លខ្ពស់ ប្រព្រឹត្តកម្មសម្ងួត ការប្រើពូជសុទ្ធ ដូចជា Bactoferm ™ F-LC ដើម្បីប្រជែង និងកម្រិតប្រែប្រួលនៃប្រព្រឹត្តកម្មកំដៅ។
- កំឡុងពេលចាប់ផ្តើមធ្វើទុក គឺពី ១៦ ទៅ ១៨ម៉ោង។
- រោគសញ្ញា ក្តៅខ្លួន ចុះពោះ រាគរូស ក្អួតចង្អោរ វាក៏ជាហានីភ័យក្នុងការធ្វើឲ្យស្ត្រីមានគភ៌រលូតកូន (១ ទៅ ៧០ថ្ងៃ)។

26

# *Campylobacter*

- ចម្លងមកសាច់សត្វស្លាបស្រស់តាមរយៈលាមក។
- *Campylobacter* វាងាយងាប់នឹងកំដៅ និងការសម្ងួត ហើយវាមិនលូតលាស់ក្នុងម្ហូបអាហារដែលមានជាតិអាស៊ីត។
- វាទ្រាំរស់ ប៉ុន្តែវាមិនលូតលាស់ក្នុងពេលក្លាសេឡើយ។

27

# *Cl. botulinum*

- វារស់នៅក្នុងដី និងពោះវៀនបក្សី។
- វាលូតលាស់ប្រសើរបំផុត ដោយគ្មានអុកស៊ីសែន និងវាអាចលូតលាស់នៅក្នុងម្ហូបអាហារដែលមានកម្រិតអាស៊ីតទាបជាច្រើន។
- pH ៤,៦ បង្ការបាក់តេរីពីការលូតលាស់ និងការផលិតតុកស៊ីន។
- ការដាក់បន្ថែមនូវស្ងួជម្រូមនីទ្រីត គឺជា hurdle មួយដែលមានប្រសិទ្ធភាពបំផុត។

28

## *Bacillus cereus* (<10.000cfu/g)

វាមាននៅជាមួយគ្រាប់ធញ្ញជាតិ ដូចជា ស្រូវ អង្ករ ធូលី និងដី។ វាបង្កើតស្ព័រ ដែលស្ព័រទាំងនោះនឹងញាស់នៅពេលចម្អិនគុយទាវ។ នៅពេលមេរោគនេះកើតកូនចៅបានគ្រប់ចំនួនសមល្មម វានឹងបង្កើតជាជាតិពុលតុកស៊ីន។ ផលអវិជ្ជមានដែលបង្កដោយតុកស៊ីន (enterotoxin) មានពីរទម្រង់ ៖

១) តុកស៊ីនក្នុងម្ហូបអាហារ ៖
- ពេលផ្តើមធ្វើទុក រយៈពេលពី ១ ទៅ ៣ ឬ ៥ម៉ោង បន្ទាប់ពីទទួលទានរួច
- រោគសញ្ញា ឈឺចុកចាប់ក្នុងពោះ ក្អួតចង្អោរយ៉ាងខ្លាំង និងមានចុះរាគខ្លះ (១២ ទៅ ២៤ ម៉ោង)។

២) តុកស៊ីនក្នុងពោះវៀន ៖
- ពេលផ្តើមធ្វើទុក រយៈពេលពី ៩ ទៅ ១៨ម៉ោង បន្ទាប់ពីទទួលទានរួច
- រោគសញ្ញា ឈឺចុកចាប់ក្នុងពោះ ចុះរាគ និងមានក្អួតខ្លះ (១ ទៅ ២ថ្ងៃ)។

29

## ៧) ត្រួតពិនិត្យអារម្មណ៍ពេលដំណាក់កាលផលិតកម្ម

- វត្ថុធាតុដើម និងគ្រឿងផ្សំទាំងអស់ មិនត្រូវមានបរិមាណមីក្រុបក្នុងកម្រិតខ្ពស់ និងមិនត្រូវមានមេរោគបង្កជំងឺ
- ត្រូវបានការពារមិនឲ្យមានការប្រឡាក់ឆ្លងដល់ផលិតផល ដោយផ្នែក ៖ ១) រូបសាស្ត្រ (ដូចជា កំទេចដែកពីគ្រឿងម៉ាស៊ីន) ២) មីក្រូជីវសាស្ត្រ (ដូចជា ភាពកង្វក់ពីដៃ និងគ្រឿងម៉ាស៊ីន) ៣) គីមីសាស្ត្រ (ដូចជា បរ៉ាក់ហ្វ័រម៉ុល ថ្នាំអង់ទីប៊ីយូទិក។ល។)
- ត្រូវបណ្តុះបណ្តាលបុគ្គលិកកម្មករពីអនាម័យម្ហូបអាហារ
- ត្រូវមានកម្មវិធីលាងសម្អាតនៅនឹងកន្លែង ដូចនេះ ទីបរិវេណផលិត និងឧបករណ៍មានសភាពស្អាតជាប្រចាំ។

30

# សូមអរគុណ

31